## ករណីមិនធានានៃ "អត្ថប្រយោជន៍លើកលែងបុព្វលាភធានារ៉ាប់រងលើការការពារអាយុជីវិត (ម្ចាស់បណ្ណសន្យារ៉ាប់រង)"

ពុំមានអត្ថប្រយោជន៍ដែលត្រូវបានធានាណាមួយ នឹងត្រូវបានទូទាត់ជូនឡើយ ប្រសិនបើព្រឹត្តិការណ៍ដែលត្រូវបានធានានោះ បង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ពីករណីណាមួយដែលបានកំណត់ខាងក្រោម។ ក្នុងករណីការបដិសេធសំណើទាមទារសំណងនោះ បណ្ដាលឱ្យបណ្ណសន្យារ៉ាប់រងនេះត្រូវបញ្ចប់សុពលភាព នោះទំនួលខុសត្រូវរបស់ក្រុមហ៊ុនដែលមានក្រោមបណ្ណសន្យារ៉ាប់រងនេះ ត្រូវកំណត់ត្រឹមការបង្វិលបុព្វលាភធានារ៉ាប់រងដែលបានបង់រួចសរុប គិតចាប់ពីកាលបរិច្ឆេទផ្ដល់ជូនបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទផ្ដល់សុពលភាពបណ្ណសន្យារ៉ាប់រងជាថ្មីឡើងវិញ (កំណត់យកកាលបរិច្ឆេទណាមួយចុងក្រោយគេ) ជូនម្ចាស់បណ្ណសន្យារ៉ាប់រងវិញ ដោយដកចេញនូវអត្ថប្រយោជន៍លើការសន្សំដែលបានទូទាត់រួច (បើមាន) និង/ឬ ការចំណាយលើការពិនិត្យសុខភាព (បើមាន) និង/ឬ ចំណាយផ្សេងៗ ដែលសមរម្យ ហើយកើតឡើងសម្រាប់ការវាយតម្លៃធានារ៉ាប់រង(បើមាន)។

### ករណីមិនធានាចំពោះករណីមរណភាព

(ក) ការសម្លាប់ខ្លួន ឬ ប៉ុនប៉ងសម្លាប់ខ្លួន ទោះបីជាម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬ មិនប្រក្រតីក៏ដោយ ក្នុងរយៈពេល ពីរ (2) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទផ្ដល់ជូនបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទផ្ដល់សុពលភាពបណ្ណសន្យារ៉ាប់រងជាថ្មីឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ (ករណីមិនធានានេះ នឹងមិនត្រូវបានអនុវត្តឡើយបន្ទាប់ពីរយៈពេលពីរ (2) ឆ្នាំ ដែលបានលើកឡើងខាងលើ) ឬ

(ខ) ការប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង។

### ករណីមិនធានាចំពោះករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

(ក) ការប៉ុនប៉ងសម្លាប់ខ្លួន ការប៉ុនប៉ងធ្វើបាបខ្លួនឯង ឬ បង្ករបួសលើខ្លួនឯងដោយចេតនា ទោះបីជាម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬ មិនប្រក្រតីក៏ដោយ ឬ

(ខ) ការប្រព្រឹត្ត ឬ ប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង ឬ

(គ) ការស្ម័គ្រចិត្តប្រើប្រាស់ សេព ឬ ស្រូប ឱសថ ឬ គ្រឿងញៀនដែលគ្មានវេជ្ជបញ្ជា សារជាតិស្រវឹង ថ្នាំពុល ឧស្ម័ន ឬផ្សែងពុល ឬ សារជាតិពុលផ្សេងៗ ឬ

(ឃ) សង្គ្រាម ឬ អំពើណាមួយដែលមានលក្ខណៈដូចគ្នានឹងសង្គ្រាម (បើទោះជាត្រូវបានប្រកាស ឬ មិនប្រកាសក៏ដោយ) ឬ កុបកម្ម ឬ ការបះបោរ ឬ ចលាចលសង្គម ឬ កូដកម្ម ឬ សកម្មភាពភេរវកម្ម បើទោះបីជាអ្នកត្រូវបានធានារ៉ាប់រងបានចូលរួម ឬ មិនចូលរួមក្នុងអំពើទាំងនោះក្ដី។